

# បទអន្តរាគន៍របស់រដ្ឋបាលឃុំសង្កាត់
# ស្តីពី
# មេរៀនបទពិសោធន៍និងបញ្ហាប្រឈម
# ពាក់ព័ន្ធនិងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
# ថ្នាក់ឃុំសង្កាត់

បង្ហាញដោយលោក ទូច ស្វាង មេឃុំអន្លង់វិល
ស្រុកសង្កែ ខេត្តបាត់ដំបង

រាជធានី ភ្នំពេញ ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ ២០១៨

## មាតិកា

១.សេចក្តីផ្តើម

២. ស្ថានភាពមុខពេលបង្កើតឱ្យមានក្រុមប្រឹក្សាឃុំ

៣. ស្ថានភាពក្រោយបង្កើតឱ្យមានក្រុមប្រឹក្សាឃុំ

៤. បញ្ហាប្រឈមរបស់រដ្ឋបាលឃុំ

៥. សំណូមពរ

## ១. សេចក្តីផ្តើម

យោងលើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ចាប់ពីឆ្នាំ ២០០២ រហូតមកដល់សព្វថ្ងៃនេះ ក្រុមប្រឹក្សាឃុំសង្កាត់ទូទាំងប្រទេសត្រូវបានបង្កើតឡើង តាមរយៈការបោះឆ្នោតជាសាកល ដែលប្រជាពលរដ្ឋបានបំពេញកាតព្វកិច្ចរបស់ខ្លួន ចូលរួមយ៉ាងសកម្មក្នុងការជ្រើសរើសតំណាងរបស់ខ្លួន។

ក្នុងរយៈពេលបីអាណត្តិកន្លងទៅនេះ ក្រុមប្រឹក្សាឃុំសង្កាត់បានបំពេញតួនាទីយ៉ាងសំខាន់ក្នុងការអនុវត្តមុខងារជាកាតព្វកិច្ច និងមុខងារជាជម្រើស ដើម្បីដោះស្រាយនូវកង្វល់ និងឆ្លើយតបទៅនិងសេចក្តីត្រូវការពិតរបស់ប្រជាពលរដ្ឋ ដែលធ្វើឱ្យមានការផ្លាស់ប្តូរកើនឡើងនូវគុណភាពជីវភាពនៅមូលដ្ឋានយ៉ាងពិតប្រាកដ។

3

## ១. ស្ថានភាពមុនពេលបង្កើតឱ្យមានក្រុមប្រឹក្សាឃុំ

មុនឆ្នាំ២០០២ រដ្ឋបាលឃុំ៖

- មេឃុំ មេភូមិ ដែលត្រូវបានជ្រើសរើស និងចាត់តាំងដោយរាជរដ្ឋាភិបាល
- សិទ្ធិអំណាចក្នុងការធ្វើសេចក្តីសម្រេចចិត្តលើការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋានមានតិចតួច
- តួនាទីតែជាអ្នកគ្រប់គ្រងប្រជាពលរដ្ឋជាជាងការងារអភិវឌ្ឍន៍មូលដ្ឋាន ដូចជាការងារគ្រប់គ្រងប្រជាជន ស្ថិតិ សន្តិសុខ ...
- មិនមានផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគដែលឆ្លុះបញ្ចាំងអំពីសេចក្តីត្រូវការ និងការឆ្លើយតបនឹងតម្រូវការជាអាទិភាព របស់ប្រជាពលរដ្ឋ។

4

## ១. ស្ថានភាពមុនពេលបង្កើតឱ្យមានក្រុមប្រឹក្សាឃុំ(ត)

- ពុំមានធនធានប្រចាំឆ្នាំរបស់ខ្លួនផ្ទាល់សម្រាប់ការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋាន។ រាល់កិច្ចអភិវឌ្ឍមូលដ្ឋាន ត្រូវបានគាំទ្រថវិកានិងការអនុវត្តដោយក្រសួង ស្ថាប័ន មន្ទីរ អង្គភាពជំនាញ ឬសប្បុរសជន..
- ពុំមានការចូលរួមទូលំទូលាយពីប្រជាពលរដ្ឋលើការងារអភិវឌ្ឍមូលដ្ឋាន
- ការចូលរួមរបស់ប្រជាពលរដ្ឋភាគច្រើនលើការការពារសន្តិសុខ
- រដ្ឋបាលឃុំ មានការទទួលខុសត្រូវចំពោះថ្នាក់លើគឺ ថ្នាក់ស្រុក ថ្នាក់ខេត្ត និងថ្នាក់ជាតិច្រើនជាងចំពោះប្រជាពលរដ្ឋ

5

## ២. ស្ថានភាពក្រោយបង្កើតឱ្យមានក្រុមប្រឹក្សាឃុំ

ចាប់ពីឆ្នាំ២០០២ រហូតមកដល់សព្វថ្ងៃនេះ រដ្ឋបាលឃុំ៖

- ក្រុមប្រឹក្សាឃុំ ត្រូវបានបង្កើតឡើង តាមរយៈការបោះឆ្នោតជាសាកលដោយផ្ទាល់ពីប្រជាពលរដ្ឋ
- ក្រុមប្រឹក្សាឃុំ បានដើរតួនាទីដ៏សំខាន់ជាតំណាងឱ្យប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ក្រុមប្រឹក្សាឃុំ មានសិទ្ធិ និងអំណាចក្នុងការធ្វើសេចក្តីសម្រេចចិត្តប្រកបដោយភាពច្បាស់លាស់ក្នុងការផ្តល់សេវានិងការអភិវឌ្ឍមូលដ្ឋាន
- ការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋាន មានការពិគ្រោះយោបល់ និងការចូលរួមពីប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធ។

6

## ២. ស្ថានភាពក្រោយបង្កើតឱ្យមានក្រុមប្រឹក្សាឃុំ(ត)

- ក្នុងអាណត្តិនីមួយៗរបស់ក្រុមប្រឹក្សាឃុំបានរៀបចំផែនការអភិវឌ្ឍ និង កម្មវិធីវិនិយោគរបស់ខ្លួនដែលមាននីតិវិធីច្បាស់លាស់ មានសុខដុមនីយកម្មជាមួយផែនការគ្រប់ថ្នាក់
- ក្រៅពីនេះ ផែនការឃុំ ក៏បានយកចិត្តទុកដាក់លើបញ្ហាអន្តរវិស័យដូចជាការគ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន ការប្រែប្រួលអាកាសធាតុ យេនឌ័រ និងសមធ៌មសង្គម
- ការផ្តល់សេវា និងការអភិវឌ្ឍប្រកាន់គោលការណ៍ជាចំបង គឺការចូលរួមពីប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធទាំងអស់ ប្រកបដោយការឆ្លើយតបទៅនឹងសេចក្តីត្រូវការជាអាទិភាពរបស់មូលដ្ឋាន ព្រមទាំងឆ្លើយតបទៅនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាលដ៏ពិតប្រាកដ។

7

## ២. ស្ថានភាពក្រោយបង្កើតឱ្យមានក្រុមប្រឹក្សាឃុំ(ត)

- តាមរយៈមូលនិធិឃុំ សង្កាត់ ក្រុមប្រឹក្សាឃុំមានធនធានប្រចាំឆ្នាំរបស់ខ្លួនសម្រាប់ការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋាន (ឆ្នាំ២០១៧ ឃុំមានមូលនិធិប្រមាណ ៣០០លានរៀល)
- ដោយផ្អែកទៅលើកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ឃុំ ក្រុមប្រឹក្សាឃុំ បានអនុវត្តន៍គម្រោងដែលមានការឆ្លើយតបទៅនិងតម្រូវការរបស់ប្រជាពលរដ្ឋ ក្នុងនោះរួមមាន ផ្លូវលំ សាលារៀន ប្រឡាយ ស្រះសហគមន៍ ទំនប់ទឹកខ្នាតតូច ទំនប់បង្ហៀរ... ការបណ្តុះបណ្តាលអំពីសុខភាពនិងអនាម័យជនបទ ការគាំទ្រថវិកាដល់ស្ត្រីសម្រាលកូន ការផ្សព្វផ្សាយពីការថែរក្សាបរិស្ថាន ការបង្កើតសាលាមត្តេយ្យសហគមន៍...។ល។

8

## ២. ស្ថានភាពក្រោយបង្កើតឱ្យមានក្រុមប្រឹក្សាឃុំ(ត)

- ក្រៅអំពីមូលនិយុំ ក្រុមប្រឹក្សាឃុំ បានកៀរគរធនធានពីប្រជាពលរដ្ឋ សប្បុរសជននិងដៃគូអភិវឌ្ឍន៍នានា
- ការចូលរួមរបស់ប្រជាពលរដ្ឋ ដូចជា កម្លាំងពលកម្ម ធនធានសម្ភារៈ ថវិកា ក្នុងការកសាង ការពារ ថែរក្សានូវសមិទ្ធផលនានាក្នុងឃុំ
- ការអនុវត្តបណ្តើរ រៀនសូត្របណ្តើរ ជាច្រើនឆ្នាំកន្លងមកនេះ បានធ្វើឱ្យក្រុមប្រឹក្សាឃុំមានសមត្ថភាព និងបទពិសោធន៍ ក្នុងការគ្រប់គ្រងរដ្ឋបាលរបស់ខ្លួនប្រកបដោយប្រសិទ្ធភាពក្នុងនាមជាតំណាងប្រជាពលរដ្ឋ។

9

## ២. ស្ថានភាពក្រោយបង្កើតឱ្យមានក្រុមប្រឹក្សាឃុំ(ត)

- ក្រុមប្រឹក្សាឃុំ មានគណនេយ្យភាពចំពោះប្រជាពលរដ្ឋក្នុងការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋាន
- លើសពីនេះទៀត ក្រុមប្រឹក្សាឃុំបានយកចិត្តទុកដាក់អនុវត្តនូវយុទ្ធសាស្ត្រគណនេយ្យភាពសង្គម ក្នុងគោលបំណងដើម្បីផ្តល់ព័ត៌មាននិងទទួលព័ត៌មាននានាឱ្យបានកាន់តែច្រើន រវាងប្រជាពលលរដ្ឋ និងរដ្ឋបាលឃុំ ដែលនេះជាសិទ្ធិស្របច្បាប់របស់ប្រជាពលរដ្ឋ ដែលរួមចំណែកធ្វើការកែលម្អក្នុងន័យស្ថាបនា ដល់ការផ្តល់សេវា និងការអភិវឌ្ឍរបស់ឃុំ។ នេះបានបង្ហាញពីចេតនាក្នុងការលើកកម្ពស់ការទទួលខុសត្រូវចំពោះប្រជាពលរដ្ឋ នូវទង្វើដែលខ្លួនបានធ្វើ និងផលវិបាកដែលនឹងកើតមានជាយថាហេតុផងដែរ។

10

## ៣. បញ្ហាប្រឈមរបស់រដ្ឋបាលឃុំ

នៅក្នុងការខិតខំប្រឹងប្រែងអនុវត្តតួនាទី ភារកិច្ចរបស់រដ្ឋបាលឃុំ ដែលធ្វើឱ្យមានការផ្លាស់ប្តូរពីបាតដៃទទេរហូត ដល់វិវត្តន៍កើនឡើងនូវកម្រិតគុណភាពជីវិតដូចសព្វថ្ងៃនេះ ក្រុមប្រឹក្សាឃុំ បានជួបនូវបញ្ហាប្រឈមមួយដែលត្រូវដោះស្រាយនិងកែលម្អដូចជាៈ

- សមត្ថភាព ចំណេះដឹងរបស់ក្រុមប្រឹក្សាឃុំនៅមានកម្រិត ជាពិសេសលើជំនាញហិរញ្ញវត្ថុដែលទាមទារឱ្យមានការរៀនសូត្រស្វែងយល់ និងធ្វើបច្ចុប្បន្នភាពជាប្រចាំ
- ការផ្លាស់ប្តូរសមាជិកក្រុមប្រឹក្សាថ្មីទាមទារឱ្យមានការអភិវឌ្ឍសមត្ថភាពឡើងវិញ
- ការងារច្រើន បុគ្គលិកបម្រើការងារតិច សមាជិកខ្លះខ្វះឆន្ទៈ ខ្វះសាមគ្គីភាពក្នុងការបំរើការងារ ហើយអ្នកមិនធ្វើចាំតែទិទៀនបំបែកបំបាក់។ 11

## ៣. បញ្ហាប្រឈមរបស់រដ្ឋបាលឃុំ (ត)

- ការទូទាត់ថវិកាដល់អ្នកទទួលការ នៅពេលខ្លះមានការយឺតយ៉ាវ ទោះបីជាឃុំបានចេញអាណត្តិបើកប្រាក់ហើយក៏ដោយ ធ្វើឱ្យគម្រោងមិនអាចអនុវត្តបានតាមកិច្ចសន្យា
- ការសិក្សាគម្រោងឃុំ មានការយឺតយ៉ាវ ដោយមន្ត្រីគាំទ្របច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធ មានគម្រោងច្រើនដែលត្រូវសិក្សា ដូចជាគម្រោងស្រុក គម្រោងប្រែប្រួលអាកាសធាតុជាដើម។

12

## ៩. សំណូមពរ

- ស្នើសុំឱ្យមានការបណ្តុះបណ្តាលពង្រឹងសមត្ថភាពដល់សមាជិកក្រុមប្រឹក្សាឃុំ លើកិច្ចការហិរញ្ញវត្ថុ នីតិវិធីនៃការអនុវត្តគម្រោងមូលនិធិឃុំសម្រាប់ឆ្នាំ២០១៨ ដែលមានការកែសម្រួល ដើម្បីពង្រឹងភាពម្ចាស់ការ ដែលកន្លងមកការងារនេះ មានការគាំទ្រយ៉ាងពេញទំហឹងពីទីប្រឹក្សាស្រុក និងការិយាល័យផែនការនិងគាំទ្រឃុំ
- ស្នើសុំបង្កើនចំនួនមូលនិធិឃុំដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋនៅមូលដ្ឋានឱ្យបានកាន់តែច្រើន
- ស្នើសុំជួយសម្រួលការតែងតាំងស្មៀនឃុំ សង្កាត់ដែលចូលនិវត្តន៍ឬផ្លាស់ប្តូរទៅបំពេញការងារនៅកន្លែងផ្សេង
- ស្នើសុំអង្គភាព ស្ថាប័នពាក់ព័ន្ធចូលរួមសហការក្នុងកិច្ចអភិវឌ្ឍឃុំ និងការផ្តល់សេវាសាធារណៈ ឱ្យកាន់តែមានប្រសិទ្ធភាព សំដៅបង្កើនទំនុកចិត្តពីសំណាក់ប្រជាពលរដ្ឋជាម្ចាស់ឆ្នោត។

13

# សមិទ្ធផលហេដ្ឋារចនាសម្ព័ន្ធរបស់រដ្ឋបាលឃុំអង្គ្លង់វិលតាមរយៈរូបភាព

14












សូមអរគុណ

19